# ចងគ្មានមុខស្រាយ

ប៉ុណ្ណ សុវណ្ណា

## Tied Knot

By Venerable Ponn Sovanna

បច្ចុប្បន្ន ជាព្រះសង្ឃគង់នៅខេត្តបាត់ដំបង។ ព្រះអង្គបានទទួលជ័យលាភី ចំណាត់ថ្នាក់លេខ៣ ពីសមាគមអក្សរសិល្បិ៍ នូ ហាច ផ្នែកកំណាព្យដែលមានចំណងជើងថា៖ ចងគ្មានមុខស្រាយ និងគុណបងយើង។

ខ្លួនជាដង្កូវនៅក្នុងបង្គន់
ក្តីទុក្ខដ៏ធ្ងន់ទារុណវាសនា
ធីតែលាមកចម្អែតអាត្មា
នេះហើយសង្ខារកើតជាដង្កូវ។

ស្គាល់ហើយលាមកគេខ្ពើមរអើម
តែព្រហ្មលិខិតដៅកំណត់ផ្លូវ
ប្រែរូបជារុយអាចហោះហើរបាន
តែនិស្ស័យកម្មទាញរុញច្រានមក

ឱ!ខ្លួនខ្ញុំអើយត្រូវគិតយ៉ាងណា
ស៊ីរបស់ស្អុយដើម្បីត្រដរ
ដង្កូវស្មឹកឈើគេអាចហើរបាន
កើតមេអំបៅហើរបានយ៉ាងខ្ពស់

អភ័ព្វតែខ្ញុំទំតែលាមក
អន់ទាំងចំណីថោកទាំងសង្ខារ

គេស្អប់គេឆ្អើមកេរ្តិ៍ឈ្មោះអាស្រូវ
ឲ្យជីវិតត្រូវតែទទួលយក។

ខំតែនឹកស្មានបានចាកជម្រក
អាហារខំរកបានតែមិនល្អ។

ឈប់ស៊ីអាហារឬមួយបន្ត
រស់ចាំថ្ងៃល្អជីវិតមានយស។

គ្មានកម្មជាប់ប្រាណមិនដែលមានគ្រោះ
គេចេះហើរត្ពោះទើរទំលើផ្កា។

ឈ្មោះក៏គម្រក់អាក្រក់កាយា
ដោយព្រេងវាសនាចារពីអតីត៕